# សុន្ទរកថារបស់លោក ឈិត សំអាត
# នាយកប្រតិបត្តិវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
# នៅក្នុង សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំ២០០៨

*ថ្ងៃព្រហស្បតិ៍ ទី២៨ ខែកុម្ភៈ ឆ្នាំ២០០៨*

*****

## "ការទាញយកផលប្រយោជន៍ឱ្យបានប្រសើរបំផុតពីធនធានធម្មជាតិកម្ពុជាៈ ព្រៃឈើ ជលផល និង រ៉ែ"

*សូមគោរព*

*- ឯកឧត្តមបណ្ឌិត* ***ច័ន្ទ សារុន*** *រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ*

*- លោកស្រី Nisha Agrawal នាយកប្រចាំប្រទេសនៃធនាគារពិភពលោក*

*- បណ្ឌិត* ***ត្នុប នេត*** *អ្នកគ្រប់គ្រងការងារស្រាវជ្រាវ កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)*

*- ភ្ញៀវកិត្តិយស ឯកឧត្តម លោកស្រី លោក ជាទីគោរព*

តាងនាមវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ខ្ញុំបាទសូមថ្លែងអំណរគុណដល់ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និង ធនាគារ ANZ Royal ដែលបានផ្តល់ឱកាសឱ្យខ្ញុំបានបញ្ចេញគំនិតដោយផ្អែកលើទស្សនៈរបស់សង្គមស៊ីវិល ស្តីពីប្រការដែលថា តើប្រទេសកម្ពុជាអាចទាញយកផលប្រយោជន៍ឱ្យបានប្រសើរបំផុតពីធនធានធម្មជាតិ ព្រៃឈើ ជលផល និង រ៉ែ របស់ខ្លួនដោយរបៀបណា?

ប្រទេសកម្ពុជាសម្បូណ៌ទៅដោយធនធានធម្មជាតិ។ សមាមាត្រគម្របព្រៃឈើ និងផ្ទៃដីរបស់កម្ពុជាដែលត្រូវបានបែងចែកទុកសម្រាប់ការពារជីវចម្រុះ គឺមានកម្រិតខ្ពស់ជាងប្រទេសជិតខាងជាច្រើន។ ធនធានព្រៃឈើ និងជលផល ផ្តល់ប្រភពជីវភាពរស់នៅដ៏សំខាន់សម្រាប់គ្រួសារក្រីក្រនៅជនបទ និងផ្តល់សុវត្ថិភាពសង្គមនៅក្នុងគ្រាមានវិបត្តិផ្សេងៗ។ ម្យ៉ាងទៀត ថ្មីៗនេះប្រទេសកម្ពុជាបានប្រែក្លាយខ្លួនទៅជាអ្នកផ្គត់ផ្គង់ធនធានធម្មជាតិ (ឈើ ផលិតផលកសិកម្ម ធនធានរ៉ែ និង ថាមពល) សម្រាប់ទីផ្សារនាំចេញក្នុងតំបន់ និងពិភពលោក ហើយគេរំពឹងថា លទ្ធភាពនេះនឹងកើនឡើងថែមទៀតដោយការរកឃើញប្រេងកាត និងឧស្ម័នធម្មជាតិ។

ប៉ុន្តែដោយសារធនធានធម្មជាតិមានកំណត់ ហើយប្រព័ន្ធអេកូឡូស៊ីក៏ផុយស្រួយ ដូច្នេះត្រូវតែចាត់ចែងយ៉ាងណាឱ្យវាមានចីរភាព ពីព្រោះធនធានធម្មជាតិទាំងនេះអាចទទួលការគម្រាមកំហែងពីការធ្វើអាជីវកម្មដោយគ្មានការគ្រប់គ្រងល្អ និងការចែកចាយអត្ថប្រយោជន៍គ្មានសមធម៌។ ដូច្នេះ ខ្ញុំបាទសូមលើកសំណួរមក

ពិភាក្សាថា តើប្រទេសកម្ពុជាអាចទាញយកផលប្រយោជន៍យ៉ាងណាឱ្យបានប្រសើរបំផុត ពីភោគទ្រព្យ ធនធានធម្មជាតិរបស់ខ្លួន ដោយមានផលចំណេញច្រើន ការថែរក្សាបរិស្ថាន និង សមធម៌?

អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិជាច្រើន បាននិងកំពុងធ្វើការងារលើបញ្ហាធនធានធម្មជាតិ។ ការងាររបស់អង្គការទាំងនេះរួមមានៈ ការអភិរក្សជីវចម្រុះមានតម្លៃខ្ពស់ ជីវភាព និងការងារផ្សព្វផ្សាយកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ ដូចជា គម្រោងសហគមន៍ព្រៃឈើ និងជលផលជាដើម និងគំនិតផ្តួចផ្តើមគោលនយោបាយ។ បទពិសោធន៍ចម្រុះទាំងនេះផ្តល់នូវទស្សនៈរយៈពេលវែងមួយ អំពីកាលានុវត្តភាព និងសមិទ្ធិផលដែលសម្រេចបាននៅក្នុងវិស័យគ្រប់គ្រងធនធានធម្មជាតិ និងការយល់ដឹងស៊ីជម្រៅអំពីហានិភ័យ និងការគម្រាមកំហែងដែលពាក់ព័ន្ធ។

ដោយសារពេលវេលាខ្លី ខ្ញុំបាទមិនអាចលើកឡើងបានច្រើននូវទស្សនៈផ្សេងៗរបស់សង្គមស៊ីវិល អំពីការគ្រប់គ្រងធនធានធម្មជាតិនេះទេ។ ខ្ញុំបាទសូមផ្តោតលើតែបញ្ហាជាក់លាក់មួយនៅក្នុងវិស័យនីមួយៗ ដើម្បីយកធ្វើជាឧទាហរណ៍សំរាប់គូសបញ្ជាក់លើទស្សនៈរបស់ក្រុមសង្គមស៊ីវិលអំពីប្រការដែលថា តើយើងទាំងអស់គ្នាអាចទាញយកផលប្រយោជន៍ឱ្យបានប្រសើរបំផុតពីភោគទ្រព្យធនធានធម្មជាតិរបស់ប្រទេសយើងយ៉ាងដូចម្តេច?

ជំពូកស្តីពីកំណែទម្រង់ព្រៃឈើនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺសំដៅថែរក្សាគម្របព្រៃឈើក្នុងកម្រិត ៦០% តាមរយៈការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ក្នុងទម្រង់ជាព្រៃគុបប្រចាំឆ្នាំ និងសម្បទានតំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ[១]។ ចក្ខុវិស័យដែលថា ព្រៃឈើអាចមានប្រយោជន៍ខាងសេដ្ឋកិច្ច ទាំងផ្នែកពាណិជ្ជកម្ម និងទាំងសម្រាប់តំបន់មូលដ្ឋាន ទន្ទឹមគ្នានឹងការអភិរក្សជីវចម្រុះ ផ្តល់នូវគម្រូមួយសម្រាប់ការគ្រប់គ្រងព្រៃឈើក្នុងលក្ខណៈសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌។ ក្រុមសង្គមស៊ីវិលមានសេចក្តីរីករាយ ជាពិសេសដោយបានឃើញគម្រោងព្រៃឈើសហគមន៍ចំនួន ១០ នៅខេត្តសៀមរាប ត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ ក្នុងឆ្នាំ២០០៧។ ទោះយ៉ាងនេះក្តី របាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នានាជាច្រើន បានលើកឡើងនូវការបារម្ភអំពីប្រការដែលថា តើអ្នកណាអាចទទួលបានផលប្រយោជន៍ពិតប្រាកដ ពីធនធានព្រៃឈើនៃប្រទេសកម្ពុជា។

ប្រការនានានៅខាងលើភាគច្រើនមានពាក់ព័ន្ធនឹងការផ្តល់ និងការអនុវត្តដីសម្បទានសេដ្ឋកិច្ច (ELCs) និងផលប៉ះពាល់អវិជ្ជមានរបស់វាលើធនធានព្រៃឈើ និងសហគមន៍ទាំងឡាយដែលពឹងអាស្រ័យលើព្រៃឈើ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងអនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច បានបញ្ជាក់ថា ការផ្តល់ដីសម្បទានសេដ្ឋកិច្ច គឺសំដៅរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទ។ ការបែងចែកសម្បទានដីសេដ្ឋកិច្ច គប្បីមានលក្ខណៈសមស្របទៅនឹងប្រព័ន្ធអេកូឡូស៊ីក្នុងមូលដ្ឋាន ជួយបង្កើតប្រាក់ចំណូលរដ្ឋ ក៏ដូចជាផ្តល់ផលចំណេញសេដ្ឋកិច្ចជូនក្រុមហ៊ុនវិនិយោគផងដែរ។ ប៉ុន្តែយើងសង្កេតឃើញថា ក្រុមហ៊ុនជាច្រើននៅទូទាំង

[១] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ទំព័រ ៥៨។

ប្រទេស កំពុងខកខានមិនបានធ្វើការងារស្របតាមច្បាប់កម្ពុជានៅឡើយ ។ ជារឿយៗណាស់ នៅមុនពេលចាប់ផ្តើមដំណើរការគំរោង ពួកគេមិនបានធ្វើការវាយតម្លៃពីផលប៉ះពាល់បរិស្ថាន ឬធ្វើការពិគ្រោះយោបល់សាធារណៈទេ ហើយអ្នកដែលរងផលប៉ះពាល់យល់ថា យន្តការតវ៉ាមិនទទួលបានការឆ្លើយតប ទៅនឹងបណ្តឹងរបស់ពួកគេឡើយ ។ ផ្ទៃដីជាងមួយលានហិកតាត្រូវបាន ផ្តល់ ឬ "យល់ព្រមជាគោលការណ៍" ឱ្យធ្វើជាផ្ទៃដីសម្បទាន[២] ប៉ុន្តែភស្តុតាងបង្ហាញថា ដីសម្បទានជាច្រើនបានដំណើរការ (កាប់ឆ្ការដី និងដើមឈើ) មុនពេលដែលកិច្ចសន្យារបស់ពួកគេត្រូវបានអនុម័ត[៣] ។ សម្បទានដីសេដ្ឋកិច្ចទាំងនេះមិនត្រឹមតែមានផលប៉ះពាល់អវិជ្ជមានលើជីវភាពរស់នៅ និងបរិស្ថានក្នុងមូលដ្ឋានប៉ុណ្ណោះទេ វាថែមទាំងមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ តំបន់ព្រៃឈើសហគមន៍ និងព្រៃឈើគោរពបូជា (ព្រៃអារក្ស) ដែលជាកម្មសិទ្ធិរបស់ជនជាតិដើមភាគតិចកម្ពុជាទៀតផង ។

នេសាទ និងការប្រមូលផលត្រី រួមចំណែកដល់ការទទួលទានប្រូតេអ៊ីនប្រមាណជា ៧០% របស់ប្រជាជនកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការសំខាន់ៗសំដៅចាត់ចែងពង្រឹងអភិបាលកិច្ចនៅក្នុងវិស័យជលផល ដើម្បីឆ្លើយតបទៅនឹងបញ្ហានានាដែលបណ្តាលមកពីការគ្រប់គ្រង ការធ្វើនេសាទត្រីទឹកសាប ពីសំណាក់សម្បទាននេសាទធំៗ ។ ច្បាប់នេសាទ និងអនុក្រឹត្យ ត្រូវបានអនុម័ត ហើយមានការដាក់បញ្ចូលសហគមន៍នេសាទ និងការបែងចែងឡើងវិញនូវតំបន់សម្បទាននេសាទជាង ៥៦% ជូនដល់ការប្រើប្រាស់តាមគ្រួសារ ។

ថ្វីបើកំណែទម្រង់ខាងច្បាប់បានទទួលការស្វាគមន៍ពីអង្គការសង្គមស៊ីវិលក្តី ក៏នៅមានការបារម្ភថា កំណែទម្រង់ទាំងនេះមិនទាន់គ្រប់គ្រាន់ដើម្បីធានាឱ្យមាន ការគ្រប់គ្រងធនធានជលផលប្រកបដោយផលចំណេញសេដ្ឋកិច្ច សមធម៌ និងការមិនខូចខាតបរិស្ថាន ។ ការបារម្ភចម្បងបំផុត គឺមានរបាយការណ៍ជាច្រើនលើកថា ការអនុវត្តច្បាប់ទាំងនេះ ជាទូទៅនៅបន្តលំអៀងជួយដល់អ្នកធ្វើពាណិជ្ជកម្មនេសាទ ដែលធ្វើឱ្យខូចប្រយោជន៍របស់អ្នកនេសាទតូចតាច ។ នៅក្នុងខេត្តខ្លះ ការបញ្ចេញ ឬការដកហូតតំបន់នេសាទពីសម្បទាននេសាទ មិនបានផ្តោតមុខព្រួញលើតំបន់នេសាទជាប្រពៃណីឡើយ ហើយការហាមឃាត់ត្រូវបានដាក់លើសហគមន៍មូលដ្ឋាន ដែលប្រើឧបករណ៍នេសាទបែបគ្រួសារ ។ បញ្ហាទាំងពីរនេះ មានផលប៉ះពាល់ធ្ងន់ធ្ងរលើជីវភាពរស់នៅក្នុងមូលដ្ឋាន ។ បន្ថែមលើនេះ សហគមន៍មូលដ្ឋាននៅតាមតំបន់ជាច្រើនមិនត្រូវបានផ្តល់ព័ត៌មានគ្រប់គ្រាន់ ឬពិគ្រោះយោបល់ អំពីការផ្លាស់ប្តូរទាំងនេះទេ ដូច្នេះអ្នកមានអំណាចនៅបន្តកាន់កាប់តំបន់នេសាទមួយចំនួនសម្រាប់គោលបំណងពាណិជ្ជកម្មដដែល ។

ក្រៅពីការចាប់អារម្មណ៍លើការគ្រប់គ្រងធនធានធម្មជាតិ គេឃើញមានការយកចិត្តទុកដាក់កាន់តែច្រើនឡើងនៅក្នុងចំណោមអង្គការសង្គមស៊ីវិលកម្ពុជា អំពី ការគ្រប់គ្រងប្រកបដោយចីរភាពនូវ <u>ប្រាក់ចំណូល</u>ធនធានធម្មជាតិ ។ តាមការពិនិត្យថវិកាជាតិក្នុងបណ្តាឆ្នាំកន្លងមកថ្មីៗនេះ គេឃើញច្បាស់ថា មានចំណូលតិចតួចណាស់ បានមកពីវិស័យព្រៃឈើ ដែលបានទៅដល់ដៃរដ្ឋាភិបាលកណ្តាល ។ ឧទាហរណ៍ ក្នុងច្បាប់ថវិកាឆ្នាំ២០០៨

---

[២] យោងតាមគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ គិតត្រឹមខែកញ្ញា ឆ្នាំ២០០៧ ។

[៣] របាយការណ៍ស៊ើបអង្កេតផ្ទៃក្នុងរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (ឆ្នាំ២០០៨) ។

ចំណូលរំពឹងទុកនៃពន្ធលើការនាំឈើចេញ និងប្រាក់ចំណូលពីសម្បទានព្រៃឈើ នៅពេលដាក់បញ្ចូលគ្នា គឺបាន ត្រឹមតែជាង បីលានដុល្លារអាមេរិកប៉ុណ្ណោះ[៤] ។ និយាយដោយសង្ខេប ការធ្វើអាជីវកម្មលើធនធានព្រៃឈើ បណ្តាលឱ្យមាន ចំណាយសង្គម និងបរិស្ថានដ៏ធំធេង ខណៈដែលអត្ថប្រយោជន៍ខាងហិរញ្ញវត្ថុមានតិចតួច ដែលមិនអាចធ្វើយុត្តិកម្មលើនិស្សារណកម្មធនធានធម្មជាតិដ៏មានតម្លៃទាំងនេះបានឡើយ ។

បទពិសោធន៍ពីវិស័យព្រៃឈើ និងជលផល ផ្តល់នូវមេរៀនដ៏មានតម្លៃសម្រាប់ការគ្រប់គ្រងប្រាក់ចំណូល ដែល នឹងហូរចូលក្នុងរយៈពេលបីឆ្នាំទៀតពីការធ្វើអាជីវកម្មលើប្រេងកាត នៅក្នុងឈូងសមុទ្រ។ ការធ្វើអាជីវកម្មនេះ នឹងនាំឱ្យមានប្រាក់ចំណូលបន្ថែមកាន់តែច្រើនឡើងសម្រាប់រាជរដ្ឋាភិបាល ហើយយោងតាម "ការប៉ាន់ស្មាន *សេដ្ឋកិច្ចសមល្មម*" របស់មូលនិធិរូបិយវត្ថុអន្តរជាតិ គឺអាចមានចំនួនដល់ ១៧៤លានដុល្លារអាមេរិកក្នុង ឆ្នាំ២០១១ និងកើនឡើងដល់ ១,៧ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ នៅឆ្នាំ២០២១។ ដើម្បីឱ្យប្រាក់ចំណូល ទាំងនេះជួយជំរុញកិច្ចអភិវឌ្ឍ ជាជាងបង្កើនអំពើពុករលួយ វិវាទ និងភាពបែកបាក់គ្នាក្នុងសង្គម ដូចជា ករណីនៃ ប្រទេសសម្បូរណ៍ធនធានដទៃទៀតមួយចំនួន គេឃើញមានភាពចាំបាច់បន្ទាន់ពីរចំណុចដែលត្រូវអនុវត្តៈ

១. តម្លាភាពទាក់ទិននឹងចំនួន ការកំណត់ពេលវេលា និងច្រកសម្រាប់ទទួល*ចំណូល*រដ្ឋាភិបាល ។

២. តម្លាភាពនៃការ*ចំណាយធនធានសាធារណៈ*។

*ឯកឧត្តម លោកស្រី លោក ជាទីគោរព*

ខ្ញុំបាទសូមបញ្ចប់សុន្ទរកថានេះ ដោយសូមលើកនូវអនុសាសន៍មួយចំនួនជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បី ចូលរួមចំណែកដល់កិច្ចប្រឹងប្រែងជួយឱ្យប្រទេសកម្ពុជា អាចទទួលបានយ៉ាងពិតប្រាកដនូវផលប្រយោជន៍ ប្រសើរ បំផុតពីភោគទ្រព្យធនធានធម្មជាតិរបស់ខ្លួន ។

ឧទាហរណ៍ទាំងពីរក្នុងវិស័យព្រៃឈើ និងជលផល បង្ហាញថា ការងារធ្វើកំណែទម្រង់អភិបាលកិច្ចធនធាន នៅមានច្រើនទៀត ក្រៅពីការផ្លាស់ប្តូរខាងច្បាប់ ។ អនុសាសន៍របស់សង្គមស៊ីវិលសម្រាប់វិស័យទាំងពីរនេះគឺៈ

១. *ពង្រឹងការអនុវត្តក្របខ័ណ្ឌគតិយុត្តិដែលទាក់ទងនិងការគ្រប់គ្រងធនធាន* ជាពិសេសការឃ្លាំមើលការ អនុវត្តរបស់ក្រុមហ៊ុនឱ្យស្របទៅតាមច្បាប់ពាក់ព័ន្ធ និងការដាក់ទោសបញ្ញត្តិលើជនទាំងឡាយណាដែល អនុវត្តដោយខុសច្បាប់ ។

២. ធានាឱ្យបានថា សហគមន៍មូលដ្ឋានដែលពឹងអាស្រ័យលើធនធានធម្មជាតិ *មានឱកាសស្មើៗគ្នាក្នុងការ ទទួលបានផលប្រយោជន៍* ពីការប្រើប្រាស់ធនធានធម្មជាតិទាំងនេះ។ ដូចមានលើកឡើងនៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បញ្ហានេះវាពាក់ព័ន្ធទាំងការធ្វើវិមជ្ឈការការងារគ្រប់គ្រងធនធាន ដោយបង្កើនការជួយគាំទ្រដល់គម្រូគ្រប់គ្រងផ្អែកលើសហគមន៍សម្រាប់វិស័យព្រៃឈើ និងជលផល

[៤] ចំណូលរំពឹងពីពន្ធលើការនាំឈើចេញៈ ៣.០៦០ (លាន) រៀល, ចំណូលរំពឹងពីសម្បទានព្រៃឈើៈ ១០.០០០ (លាន) រៀល។

និងទាំងការធានាឱ្យបានផងដែរថា វិនិយោគិនពាណិជ្ជកម្មបានពិគ្រោះយោបល់យ៉ាងគ្រប់គ្រាន់ជាមួយ និងឆ្លើយតបទៅកាន់ប្រជាជនក្នុងមូលដ្ឋានដែលរងផលប៉ះពាល់ពីប្រតិបត្តិការរបស់ខ្លួន[៥] ។

សំរាប់ការគ្រប់គ្រងប្រាក់ចំណូលប្រេងកាតរបស់ប្រទេសកម្ពុជាឱ្យបានល្អ ខ្ញុំសូមចូលរួមជាអនុសាសន៍ពីរ ដូចតទៅ:

៣. *អនុម័ត និងអនុវត្តគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណ* ដែលបច្ចុប្បន្ននេះកំពុងត្រូវបានពិនិត្យពិចារណាដោយរាជរដ្ឋាភិបាល ។ គំនិតផ្តួចផ្តើមនេះនឹងជួយឱ្យប្រទេសកម្ពុជាអាចៈ

- ជៀសវាងបាននូវការកេងបន្លំប្រាក់ចំណូលដោយសាជីវកម្ម ឬ ដោយតួអង្គរដ្ឋ ។
- បង្កើតក្របខ័ណ្ឌគណនេយ្យភាពមួយពីសំណាក់ក្រុមហ៊ុនធំៗ និងរដ្ឋាភិបាល ជូនចំពោះ ម្ចាស់ពិតប្រាកដលើធនធានធម្មជាតិ ពោលគឺប្រជាពលរដ្ឋកម្ពុជា ។

៤. *ផ្សព្វផ្សាយជាសាធារណៈនូវឯកសារថវិកាមានស្រាប់:*

- ទិន្នន័យអំពីការអនុវត្តថវិកាតាមក្រសួង ដូចដែលមានកត់ត្រាដោយ រតនាគារជាតិ[៦] ការបោះផ្សាយស្ថិតិប្រចាំខែ លើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- របាយការណ៍នានាពីអាជ្ញាធរសវនកម្មជាតិ ស្តីពីការអនុវត្តថវិកា ដែលត្រូវបានដាក់ជូនរដ្ឋសភាជាតិ ប៉ុន្តែបច្ចុប្បន្ននេះ នៅរក្សាទុកជាការសម្ងាត់នៅឡើយ ។

*សូមអរគុណឯកឧត្តម លោកស្រី លោក ដែលបានយកចិត្តទុកដាក់ស្តាប់ ។*

---

[៥] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ទំព័រ ៩៧-៩៩។

[៦] នៅពេលសរសេរសុន្ទរកថានេះ (ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៨) ព័ត៌មានចុងក្រោយបំផុតដែលមាននៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺព្រឹត្តិប័ត្រស្ថិតិប្រចាំខែ ពីខែសីហា ឆ្នាំ២០០៧។ ព្រឹត្តិប័ត្រនេះមិនមានព័ត៌មានតាមក្រសួងទេ មានតែតួលេខដុលអំពីប្រាក់ខែ ប្រាក់ចំណូលពីម្ចាស់ជំនួយផ្សេងៗ ។ល។ ដែលមិនមានប្រយោជន៍ទេសម្រាប់ការឃ្លាំមើល ។